**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៦៧៧ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៣១៩គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញលិខិតលេខ ៤៦៧អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៦៧៧ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៦៤១ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៣៦ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងខ្ពុំ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣១៩គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិត្រពាំងខ្ពុំ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។



www.pheakdeylaw.com

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ ៥៤៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ១៥៦,៨០ហិកតា ចេញពីដែនដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១២២គ្រួសារ ឆ្វៀលដីទំហំ ១៥២,៧៨ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងដីផ្លូវជាក់ស្តែង និងដីទំហំ ៤,០២ហិកតា ក្រោយមកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិក្រាំងខ្មុំ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ





ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ២៥៤.អនក្រ.បក. ចុះថ្ងៃទី១៥....ខែធ្នូ...ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ៦៧៧,០០ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៦៩គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ




តារាងចំណុចនិយាមកា

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 441511 | 1244758 | 65 | 438474 | 1244870 | 129 | 439927 | 1244901 |
| 2 | 441547 | 1244891 | 66 | 438537 | 1244627 | 130 | 440095 | 1244895 |
| 3 | 441663 | 1245127 | 67 | 438568 | 1244573 | 131 | 440097 | 1244833 |
| 4 | 441684 | 1245136 | 68 | 438608 | 1244558 | 132 | 440141 | 1244828 |
| 5 | 441722 | 1245311 | 69 | 439263 | 1244554 | 133 | 440130 | 1244747 |
| 6 | 441774 | 1245445 | 70 | 439252 | 1244526 | 134 | 440095 | 1244747 |
| 7 | 441781 | 1245478 | 71 | 439248 | 1244500 | 135 | 440095 | 1244784 |
| 8 | 441746 | 1245532 | 72 | 439414 | 1244486 | 136 | 440094 | 1244800 |
| 9 | 441725 | 1245541 | 73 | 439442 | 1244820 | 137 | 440069 | 1244810 |
| 10 | 441682 | 1245531 | 74 | 439500 | 1244597 | 138 | 440029 | 1244809 |
| 11 | 441583 | 1245533 | 75 | 439510 | 1244591 | 139 | 440029 | 1244842 |
| 12 | 441579 | 1245538 | 76 | 439537 | 1244583 | 140 | 440019 | 1244841 |
| 13 | 441629 | 1245652 | 77 | 439573 | 1244588 | 141 | 440011 | 1244853 |
| 14 | 441541 | 1245731 | 78 | 439565 | 1244533 | 142 | 439927 | 1244844 |
| 15 | 441390 | 1246099 | 79 | 439589 | 1244526 | 143 | 439926 | 1244805 |
| 16 | 441264 | 1246148 | 80 | 439583 | 1244501 | 144 | 439933 | 1244804 |
| 17 | 441029 | 1246245 | 81 | 439610 | 1244500 | 145 | 439936 | 1244654 |
| 18 | 440989 | 1246367 | 82 | 439515 | 1244477 | 146 | 440013 | 1244622 |
| 19 | 440916 | 1246571 | 83 | 439620 | 1244476 | 147 | 440015 | 1244412 |
| 20 | 440910 | 1246578 | 84 | 439621 | 1244463 | 148 | 440087 | 1244395 |
| 21 | 440867 | 1246614 | 85 | 439624 | 1244457 | 149 | 440089 | 1244178 |
| 22 | 440625 | 1246685 | 86 | 439618 | 1244422 | 150 | 440087 | 1244479 |
| 23 | 440631 | 1246621 | 87 | 439633 | 1244423 | 151 | 440093 | 1244639 |
| 24 | 440411 | 1246663 | 88 | 439640 | 1244456 | 152 | 440478 | 1244577 |
| 25 | 440431 | 1246765 | 89 | 439661 | 1244455 | 153 | 440454 | 1244672 |
| 26 | 440330 | 1246794 | 90 | 439662 | 1244480 | 154 | 440451 | 1244685 |
| 27 | 440622 | 1246786 | 91 | 439674 | 1244457 | 155 | 440472 | 1244705 |
| 28 | 440681 | 1247062 | 92 | 439689 | 1244422 | 156 | 440439 | 1244623 |
| 29 | 440669 | 1247189 | 93 | 439844 | 1244392 | 157 | 440519 | 1244620 |
| 30 | 440388 | 1247272 | 94 | 439871 | 1244411 | 158 | 440528 | 1244717 |
| 31 | 440363 | 1247163 | 95 | 439881 | 1244414 | 159 | 440512 | 1244719 |
| 32 | 440184 | 1247218 | 96 | 439922 | 1244411 | 160 | 440503 | 1244718 |
| 33 | 440180 | 1247184 | 97 | 439911 | 1244433 | 161 | 440605 | 1244791 |
| 34 | 440037 | 1247216 | 98 | 439941 | 1244489 | 162 | 440610 | 1244759 |
| 35 | 440020 | 1247159 | 99 | 439941 | 1244511 | 163 | 440637 | 1244729 |
| 36 | 439818 | 1247226 | 100 | 439875 | 1244539 | 164 | 440625 | 1244712 |
| 37 | 439706 | 1247071 | 101 | 439891 | 1244644 | 165 | 440656 | 1244715 |
| 38 | 439707 | 1246942 | 102 | 439740 | 1244666 | 166 | 440669 | 1244711 |
| 39 | 439668 | 1246730 | 103 | 439734 | 1244826 | 167 | 440672 | 1244699 |
| 40 | 439650 | 1246566 | 104 | 439746 | 1244900 | 168 | 440718 | 1244685 |
| 41 | 439614 | 1246379 | 105 | 439742 | 1244900 | 169 | 440758 | 1244695 |
| 42 | 439541 | 1246272 | 106 | 439752 | 1244943 | 170 | 440756 | 1244681 |
| 43 | 439416 | 1246204 | 107 | 439743 | 1244944 | 171 | 440760 | 1244647 |
| 44 | 439353 | 1246172 | 108 | 439743 | 1244950 | 172 | 440745 | 1244631 |
| 45 | 439297 | 1246003 | 109 | 439749 | 1244968 | 173 | 440893 | 1244642 |
| 46 | 439291 | 1245902 | 110 | 439763 | 1245021 | 174 | 440919 | 1244631 |
| 47 | 439319 | 1245794 | 111 | 439760 | 1245032 | 175 | 440950 | 1244622 |
| 48 | 439240 | 1245753 | 112 | 439768 | 1245037 | 176 | 441007 | 1244617 |
| 49 | 439188 | 1245685 | 113 | 439781 | 1245077 | 177 | 441037 | 1244625 |
| 50 | 439033 | 1245684 | 114 | 439775 | 1245095 | 178 | 441039 | 1244646 |
| 51 | 439004 | 1245615 | 115 | 439783 | 1245120 | 179 | 441085 | 1244662 |
| 52 | 438873 | 1245559 | 116 | 439791 | 1245119 | 180 | 441088 | 1244674 |
| 53 | 438827 | 1245471 | 117 | 439797 | 1245163 | 181 | 441099 | 1244672 |
| 54 | 438926 | 1245439 | 118 | 439833 | 1245171 | 182 | 441117 | 1244705 |
| 55 | 438896 | 1245350 | 119 | 439843 | 1245183 | 183 | 441133 | 1244700 |
| 56 | 438834 | 1245378 | 120 | 439923 | 1245154 | 184 | 441210 | 1244698 |
| 57 | 438776 | 1245230 | 121 | 439941 | 1245138 | 185 | 441218 | 1244723 |
| 58 | 438765 | 1245171 | 122 | 439954 | 1245134 | 186 | 441248 | 1244728 |
| 59 | 438836 | 1245125 | 123 | 440017 | 1245074 | 187 | 441275 | 1244727 |
| 60 | 438828 | 1245055 | 124 | 440003 | 1245036 | 188 | 441285 | 1244740 |
| 61 | 438751 | 1244967 | 125 | 439999 | 1245004 | 189 | 441310 | 1244744 |
| 62 | 438576 | 1244855 | 126 | 439991 | 1244995 | 190 | 441323 | 1244767 |
| 63 | 438510 | 1244715 | 127 | 439990 | 1244969 | 191 | 441372 | 1244753 |
| 64 | 438479 | 1244711 | 128 | 439933 | 1244973 | 192 | 441498 | 1244737 |